

យុវវ័យ

*ទទួលបានយោបល់នានាពីគេហទំព័រ lds.org/go/6176. #futuremissionary*

# អ្នកផ្សព្វផ្សាយសាសនាគ្មានស្លាកឈ្មោះ

ដោយ យើស៊្វី អារេវ

នៅសាលារៀនខ្ញុំមានគ្រូបង្រៀនម្នាក់ គាត់ជាប្រភេទមនុស្សដែលអាចបំភ័យដល់នរណាម្នាក់កុំឲ្យចែកចាយទស្សនៈប្រឆាំងរបស់ខ្លួនលើប្រធានបទណាមួយ ។ ថ្ងៃមួយយើងបានពិភាក្សាប្រធានបទស្ដីពីពួកអ្នកផ្សព្វផ្សាយសាសនា អិល.ឌី.អេស ។ ខ្ញុំដឹងថាខ្ញុំអាចឆ្លើយសំណួររបស់គាត់បាន ប៉ុន្តែខ្ញុំមានអារម្មណ៍ថាខ្ញុំពុំគួរឆ្លើយឡើយ ។ ដូច្នេះខ្ញុំគ្រាន់តែបាននិយាយល្មមនឹងផ្គាប់ចិត្តគាត់ក្នុងគ្រានោះ ។

ពីរបីសប្ដាហ៍ក្រោយមក ខ្ញុំពុំអាចឈប់គិតអំពីការសន្ទនារបស់យើងនោះបានឡើយ ។ ទីបំផុត មានគំនិតមួយបានផុសឡើងក្នុងចិត្តខ្ញុំថា ខ្ញុំគួរតែជូនព្រះគម្ពីរមរមនមួយក្បាលឲ្យគាត់ ដោយមានគូសចំណាំឃ្លានានាអំពីកិច្ចការផ្សព្វផ្សាយសាសនា ។ គំនិតនោះបានធ្វើឲ្យខ្ញុំខ្លាច ប៉ុន្តែវាដក់នៅជាប់ក្នុងចិត្តខ្ញុំជានិច្ច ។ ខ្ញុំដឹងថា នោះគឺជាការបំផុសគំនិតមួយដែលខ្ញុំត្រូវធ្វើតាម ។

*មានគំនិតមួយបានផុសឡើងក្នុងចិត្តខ្ញុំថា ខ្ញុំគួរតែជូនព្រះគម្ពីរមរមនមួយក្បាលឲ្យគាត់ ។*

ប្រហែលជាពីរខែក្រោយមក ខ្ញុំបានរៀបចំព្រះគម្ពីរមរមននោះរួចជាស្រេច ។ អស់ពេលមួយថ្ងៃពេញ ខ្ញុំមានអារម្មណ៍អន្ទះអន្ទែងចង់ឲ្យគម្ពីរនោះទៅគាត់ណាស់ ។ វាចំណាយពេលតែបីវិនាទីប៉ុណ្ណោះសម្រាប់ខ្ញុំ ដើម្បីជូនគម្ពីរនោះទៅគាត់ ពីមុនខ្ញុំឈប់សម្រាកវិស្សមកាលនារដូវរងារ ហើយវាជាគ្រាដ៏ភ័យខ្លាចបំផុតក្នុងជីវិតរបស់ខ្ញុំ ។

នៅថ្ងៃទីមួយដែលខ្ញុំចូលបរវេសកាលវិញ ខ្ញុំបានដើរកាត់មុខថ្នាក់រៀនរបស់គាត់ ប៉ុន្តែខ្ញុំខ្លាចពុំហ៊ានដើរចូលទៅក្នុងថ្នាក់ឡើយ ។ ក្រោយមកខ្ញុំបានឮគាត់ហៅខ្ញុំ ហើយគាត់បានឲ្យសំបុត្រមួយមកខ្ញុំ ។ ខ្ញុំបានអានសំបុត្រនោះនៅតាមផ្លូវ ។ គាត់បានសរសេរថា គាត់បានសិក្សា « យ៉ាងលម្អិត » នូវវគ្គបទគម្ពីរដែលខ្ញុំបានគូសចំណាំ ហើយគាត់បានចាប់ផ្ដើមយល់ពីហេតុផលដែលបង្កប់នៅក្នុងសេចក្ដីជំនឿរបស់ខ្ញុំ ។

ឥឡូវនេះខ្ញុំមានចិត្តរំភើបក្នុងការចែកចាយដំណឹងល្អ ហើយខ្ញុំកាន់តែមានចិត្តរំភើបក្នុងការបម្រើបេសកកម្មថ្វាយដល់ព្រះវរបិតាសួគ៌របស់ខ្ញុំក្នុងពេលឆាប់ៗនេះ ។

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

កុមារ

# ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា

ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានហៅឲ្យបង្រៀនដំណឹងល្អ ហើយក៏ហៅដើម្បីបម្រើមនុស្សផងដែរ ។ សូមជួយអ្នកផ្សព្វផ្សាយសាសនានេះ ស្វែងរកឧបករណ៍នានាដែលបានលាក់ក្នុងរូបភាពនេះ !





រូបភាពគំនូរដោយ មីតែល ណេលសិន